**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**អគ្គនាយកដ្ឋានស្រាវជ្រាវ**

**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- រាជរដ្ឋាភិបាលកម្ពុជា បានឱ្យសង់រោងចក្រកែច្នៃផ្លែឈើតម្លៃ ១១ លានដុល្លារនៅខេត្តកំពង់ស្ពឺ
- វិស័យភោជនីយដ្ឋានធ្លាក់ចុះលើស ៥០% ដោយសារវិបត្តិកូវីដ ១៩
- តើសហគ្រិនស្ត្រីជួបបញ្ហាអ្វីខ្លះ ក្នុងការទទួលបានកម្ចីពីគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ?
- ផ្សារមូលបត្រកម្ពុជា ត្រៀមខ្លួនទទួលក្រុមហ៊ុនបោះផ្សាយលក់មូលបត្រចំណុលទី ១ ប្រចាំឆ្នាំ ២០២១
- រយៈពេល៨ខែឆ្នាំនេះ កម្ពុជាទទួលបានផលវារីវប្បកម្មជាង១៥១តោន
- ស្រូវវស្សាជាច្រើនហិកតា នៅស្រុកក្រឡាញ់ បានក្រៀមស្វិត និងប្រឈមងាប់ដោយសារអត់ទឹក
- កម្ពុជាស្នើប្រទេសថៃជួយជំរុញទេសចរណ៍ បន្ទាប់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ មានសភាពធូរស្រាល
- ប្រទេសវៀតណាមគឺជាទីផ្សារធំសម្រាប់ស្វាយកម្ពុជា
- គណនីចរន្តរបស់ប្រទេសម៉ាឡេស៊ីអតិរេក RM ១៤,៤ ប៊ីលានក្នុងត្រីមាសទី២ ឆ្នាំ២០២១
- វិស័យនាំចេញថៃ បន្តកើនឡើងនៅខែកក្កដា ថ្វីបើមានការបន្តផ្ទុះឡើងនៃវិបត្តិជំងឺកូវីដ-១៩
- ក្រសួងអំពាវនាវឱ្យអ្នកនាំចេញទំនិញទៅចក្រភពអង់គ្លេស ចូលរួមផ្តល់យោបល់ក្នុងដំណើរការរៀបចំសេចក្តីព្រាងយន្តការអនុគ្រោះពន្ធ
- វិបត្តិជំងឺរាតត្បាត បានគម្រាមកំហែងដល់វឌ្ឍនភាពនៃគោលដៅអភិវឌ្ឍពិភពលោករបស់អាស៊ី-ប៉ាស៊ីហ្វិក
- កូវីដ Delta ធ្វើឱ្យក្តីសង្ឃឹមនៃការងើបឡើងវិញសេដ្ឋកិច្ចនៅអាស៊ីធ្លាក់ចុះ
- IMF បែងចែកទុនបម្រុងចំនួន ៦៥០ប៊ីលានដុល្លារ ដើម្បីជួយទ្រទ្រង់សេដ្ឋកិច្ចពិភពលោក


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៤ ខែសីហា ឆ្នាំ២០២១ លេខ ៖ ៨២

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ភ្លើងខៀវ ឱ្យសង់រោងចក្រកែច្នៃផ្លែឈើតម្លៃ ១១ លានដុល្លារនៅខេត្តកំពង់ស្ពឺ




*ដោយ Dy Bunnara*

ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា បានអនុញ្ញាតិឱ្យមានរោងចក្រកែច្នៃផ្លែឈើនៅខេត្តកំពង់ស្ពឺ ដោយបានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ជូនដល់ក្រុមហ៊ុន CAMBODIAN XING CAN SHI PIN CO., LTD. L. លើគម្រោងបង្កើតរោងចក្រកែច្នៃផ្លែឈើ (ដំណាប់ស្វាយ, ម្នាស់, មៀន, ខ្នុរ និងស្វាយចន្ទី) ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិតាំងស្រឹង ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានទុនវិនិយោគប្រមាណ ១១,២លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ១៥៤នាក់។ នៅក្នុងនោះដែរ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរជូនក្រុមហ៊ុនជាច្រើនទៀត មានដូចជា៖

១. ETHAN METAL MANUFACTURE CO., LTD. គម្រោងបង្កើតរោងចក្រកែច្នៃអាលុយមីញ៉ូម ដែក និងទង់ដែង (ពីវត្ថុធាតុដើមចាស់ៗប្រមូលទិញក្នុងស្រុក) ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល។

២. SOMA ENERGY CO., LTD. គម្រោងបង្កើតស្ថានីយផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៥មេហ្គាវ៉ាត់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិសំបួរ ឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំ។

៣. SCHNEITEC ALTERNATIVE CO., LTD. គម្រោងបង្កើតរោងចក្រផលិតថាមពលអគ្គិសនីដើរដោយប្រេងខ្មៅ អានុភាព២៣មេហ្គាវ៉ាត់ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៤. XIN CHENHUI (CAMBODIA) CHEMICAL INDUSTRY CO., LTD. គម្រោងបង្កើតរោងចក្រផលិតជីរគីមី ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិដំបងវេញ ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

៥. SOMA FARM (CAMBODIA) CO., LTD. គម្រោងបង្កើតកសិដ្ឋានចិញ្ចឹមសត្វ (មាន់, ទា, ជ្រូក...) ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិខ្នារ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។

៦. CAMBODIAN A1 STEEL INDUSTRY CO., LTD. គម្រោងបង្កើតរោងចក្រកែច្នៃដែកគ្រប់ប្រភេទ ដែលមានទីតាំងវិនិយោគស្ថិតនៅភូមិស្លុកល្ពៅ ឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ កម្ពុជាថ្មី ចេញផ្សាយថ្ងៃអង្គារ ទី២៤ ខែសីហា ឆ្នាំ២០២១*

## វិស័យភោជនីយដ្ឋានធ្លាក់ចុះលើស ៥០% ដោយសារវិបត្តិកូវីដ ១៩



*ប្រភព ៖ ភ្នំពេញប៉ុស្តិ៍*

តួលេខចុងក្រោយពីសមាគមភោជនីយដ្ឋានកម្ពុជា (CRA) បានឱ្យដឹងថា ការលក់នៅក្នុងឧស្សាហកម្មនេះបានធ្លាក់ចុះ ៥០% កាលពីឆ្នាំ២០២០ ធៀបឆ្នាំ ២០១៩។ សម្រាប់ឆ្នាំ ២០២១នេះ ការលក់ក្នុងឧស្សាហកម្មនេះនៅបន្តធ្លាក់ចុះប្រហែល៦០%ធៀបនឹងឆ្នាំ ២០២០។

ម្ចាស់ភោជនីយដ្ឋានជាច្រើននិយាយថា ជំងឺកូវីដ ១៩ បានបង្ខំឱ្យបិទទីតាំងអាហារដ្ឋាន ព្រោះមិនមានភ្ញៀវចូលហូប ពិសេសអាហារថ្ងៃត្រង់នៅតាមភោជនីយដ្ឋាន។ ប្រធាន CRA បានប៉ាន់ប្រមាណថា អតិថិជនដែលចូលអង្គុយហូបអាហារនៅតាមភោជនីយដ្ឋានបានធ្លាក់ចុះ ៨៥% ចាប់តាំងពីការរីករាលដាលជំងឺកូវីដ ១៩ ក្រៅពីនោះមានការបញ្ជាទិញដោយវេចខ្ចប់ប៉ុណ្ណោះ ប៉ុន្តែមានប្រមាណជា១៦%ប៉ុណ្ណោះ ជំនួសឱ្យការចូលហូបនៅក្នុងភោជនីយដ្ឋាន។ ឧស្សាហកម្មនេះថមថយបន្តិចម្តងៗ ហើយយើងក៏កំពុងស្វែងយល់ពីរបៀបចែកចាយថ្មី។

លោកបន្តលើកឡើងថា យើងមិនអាចផ្លាស់ប្តូរវិបត្តិនេះបានទេ ការបិទទ្វារ ឬដំណើរការដែលនឹងកើតមាននៅពេលខាងមុខ ប៉ុន្តែពួកគេអាចនឹងបានផ្លាស់ប្តូរប្រតិបត្តិការរបស់ពួកគេ តែទំនងជាប្រើរយៈពេលយូរទម្រាំជំងឺនេះផុតរលត់ទៅ។

លោកបានបន្ថែមថា រទេះលក់អាហារតាមផ្លូវ អាហាររហ័ស ឬសេវាកម្មម្ហូបអាហារតាមបញ្ជរ កំពុងមានភាពប្រសើរ ដោយសារផលិតផលរបស់ពួកគេមានតម្លៃសមរម្យ និងងាយស្រួលក្នុងការវេចខ្ចប់ និងកាត់បន្ថយសេវាកម្មបម្រើដោយមនុស្ស។

លោកបន្ថែមថា៖ ចាប់តាំងពីការរីករាលដាលកូវីដ ១៩ មក សហគ្រាស ធុនតូច និងមធ្យមពាក់កណ្តាលនៅក្នុងឧស្សាហកម្មនេះបានបាត់មុខ ហើយយើងរំពឹងថានឹងបិទទ្វារកាន់តែច្រើនទៀតនៅក្នុងពេលដ៏ខ្លីខាងមុខ។

ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំនៃអគ្គនាយកដ្ឋានពន្ធដារបានបញ្ជាក់ថា រដ្ឋាភិបាលបានដាក់ចេញវិធានការអន្តរាគមន៍មួយចំនួន ដើម្បីជួយដល់ម្ចាស់អាជីវកម្ម ក្នុងអំឡុងពេលវេលាដ៏ពិបាកនេះ។

អគ្គនាយកក្រុមហ៊ុនCIM Holdingបានឱ្យដឹងថា វិស័យបដិសណ្ឋារកិច្ច កំពុងធ្លាក់ចុះយ៉ាងរហ័ស ទោះបីមានការគាំទ្ររបស់រដ្ឋាភិបាលក៏ដោយ និងចាំបាច់ត្រូវមានផែនការស្តារងើបឡើងវិញ ដែលរួមបញ្ចូលទាំងការលើកទឹកចិត្តពន្ធដើម្បីជំរុញការវិនិយោគរយៈពេលវែង និងមាននិរន្តរភាព។ រាជរដ្ឋាភិបាលគួរតែពិចារណាចំពោះការអនុញ្ញាតឱ្យក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតជាមធ្យោបាយស្តារឧស្សាហកម្មឡើងវិញ ជំរុញការវិនិយោគ និងលើកកម្ពស់ភាពធន់ក្នុងរយៈពេលមួយល្អបំផុត៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១។*

## តើសហគ្រិនស្ត្រីជួបបញ្ហាអ្វីខ្លះ ក្នុងការទទួលបានកម្ចីពីគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ?




*ប្រភព ៖ ខេមបូណ្ឌមីស*

ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា បានសង្កេតឃើញថា សហគ្រិនជាស្ត្រីមួយចំនួនជួបការលំបាកក្នុងការទទួលបានកម្ចីបើកអាជីវកម្ម និងពង្រីកមុខរបរ ក៏ព្រោះតែការយល់ដឹងក្នុងការគ្រប់គ្រង និងការធ្វើផែនការហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ។

ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សហគ្រិនជាស្ត្រីក្នុងការទទួលបានហិរញ្ញប្បទាន សមាគមសហគ្រិនស្ត្រីកម្ពុជា បានចុះ MOU ជាមួយសមាគមធនាគារ និងសមាគមមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្នុងការផ្តល់នូវចំណេះដឹងផ្នែកហិរញ្ញវត្ថុថ្មីៗដល់សហគ្រិនជាស្ត្រីយកទៅអនុវត្តក្នុងអាជីវកម្ម និងពង្រីកមុខរបររបស់ពួកគេកាន់តែធំថែមទៀត។

ជាមួយគ្នានេះ ប្រធានសមាគមធនាគារនៅកម្ពុជា បានចាត់ទុកការចុះ MOU ជាសក្ខីភាពនៃកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ និងបញ្ជ្រាបការយល់ដឹងផ្នែកហិរញ្ញវត្ថុ ពិសេស លើកកម្ពស់ការយល់ដឹងលើការទទួលបានហិរញ្ញប្បទានរបស់សហគ្រិនស្ត្រី និងសហគ្រាសធុនតូច និងមធ្យម ពីបណ្តាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

ប្រធានក្រុមប្រឹក្សាភិបាលស្តីទីនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក៏សង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងបី នឹងក្លាយជាចលករក្នុងការជួយជំរុញការអភិវឌ្ឍអាជីវកម្ម ដែលគ្រប់គ្រងដោយសហគ្រិនជាស្ត្រីឱ្យកាន់តែរីកចម្រើន និងរឹងមាំថែមទៀត។ លោកបានគូសបញ្ជាក់បន្ថែមថា ក្នុងចំណោមអតិថិជនជិត ២លាននាក់របស់វិស័យមីក្រូហិរញ្ញវត្ថុ អតិថិជនភាគច្រើនលើសលុបជាស្ត្រី។

ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា បានស្នើឱ្យធនាគារ និងមីក្រូហិរញ្ញវត្ថុបន្ធូរបន្ថយបែបបទ ឬ លក្ខខណ្ឌកម្ចីដល់សហគ្រិនជាស្ត្រី ដើម្បីឱ្យពួកគាត់មានលទ្ធភាពទទួលបានដើមទុនក្នុងការបើក និង ពង្រីកអាជីវកម្មក្នុងអំឡុងពេលវិបត្តិកូវីដ១៩ បាននឹងកំពុងបន្តអូសបន្លាយ។ បន្ថែមពីលើនេះ សមាគមសហគ្រិនស្ត្រីកម្ពុជាស្នើឱ្យស្ថាប័នហិរញ្ញវត្ថុ ដែលផ្តល់កម្ចី ជួយបញ្ចុះអត្រាការប្រាក់ដល់សហគ្រិនជាស្ត្រី ដើម្បីជួយលើកកម្ពស់សមភាពយេនឌ័រ និងស្ត្រីក្នុងវិស័យជំនួញ៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយមួយសប្តាហ៍មុន។*

## ផ្សារមូលបត្រកម្ពុជា ត្រៀមខ្លួនទទួលក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុលទី ១ ប្រចាំឆ្នាំ ២០២១




*រូបភាព ៖ ងួន សុភ័ក្ត្រា*

ក្រុមហ៊ុន Telcotech នឹងក្លាយជាក្រុមហ៊ុនទី ១ បោះផ្សាយលក់សញ្ញាប័ណ្ណ ឬមូលបត្របំណុល នៅក្នុងឆ្នាំ ២០២១ដែលអាចជួញដូរ។

ក្រុមហ៊ុន Telcotech ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៧ និងជាក្រុមហ៊ុនឈានមុខគេមួយ ក្នុងវិស័យសេវាទូរគមនាគមន៍សាធារណៈនៅកម្ពុជា ដែលរួមមាន សេវាអ៊ិនធឺណេត សេវាCloud និងមជ្ឈមណ្ឌលទិន្នន័យ ជាដើម។

អគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានគូសបញ្ជាក់ដែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានសម្រេចឯកភាពជាគោលការណ៍លើ ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីរបស់ក្រុមហ៊ុន Telcotech រួចរាល់ហើយ តែយ៉ាងណាក៏ដោយ សម្រាប់ព័ត៌មានលម្អិត ទាក់ទងនឹងការបោះផ្សាយ អាចនឹងជម្រាបជូនបាននៅពេលខាងមុខ។

ការបោះផ្សាយលក់សញ្ញាប័ណ្ណ ឬមូលបត្របំណុលរបស់ក្រុមហ៊ុន Telcotech គឺមានលក្ខណៈពិសេសដែលអនុញ្ញាតឱ្យតែវិនិយោគិនមានគុណវុឌ្ឍិអាចធ្វើការជួញដូររវាងគ្នាបាន។ ការបោះផ្សាយលក់សញ្ញាប័ណ្ណប្រភេទនេះ សបញ្ជាក់ពីសក្តានុពលរបស់ក្រុមហ៊ុន ហើយក៏ទទួលបាននូវការធានាពីស្ថាប័ន Credit Guarantee and Investment Facility ដែលស្ថិតក្រោម ធនាគារអភិវឌ្ឍន៍អាស៊ីADB និងម្ចាស់ហ៊ុននៅក្នុងតំបន់អាស៊ានបូក៣ រួមទាំងប្រទេសកម្ពុជាផងដែរ។ ដូច្នេះ វិនិយោគិនអាចនឹងពិចារណា ចំពោះការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ឬអាចបោះផ្សាយលក់ជូនវិនិយោគិនគុណវុឌ្ឍិ ដោយភ្ជាប់នូវលក្ខខណ្ឌពិសេសដូចគ្នា។ ចំពោះគុណសម្បត្តិនៃការបោះផ្សាយលក់មូលបត្រ សម្រាប់តែវិនិយោគិនគុណវុឌ្ឍិ គឺមានភាពឆាប់រហ័សក្នុងការបញ្ចប់នីតិវិធី និងឆាប់ទទួលបានដើមទុនសម្រាប់យកមកប្រើប្រាស់ ប៉ុន្តែជាគុណវិបត្តិវិញ គឺវិនិយោគិន ដែលបានទិញមូលបត្រនេះ មិនអាចលក់ជាសាធារណៈបានទេ ចាំបាច់ត្រូវលក់ជូនវិនិយោគិនគុណវុឌ្ឍិ ដូចគ្នាតែប៉ុណ្ណោះ។

បើទោះបីជាមានការរំខានពីវិបត្តិមេរោគកូវីដ១៩ ក៏មានក្រុមហ៊ុន ៤ផ្សេងទៀត កំពុងតែរៀបចំខ្លួន ចូលមកទីផ្សារមូលបត្រកម្ពុជា ក្នុងពេលឆាប់ៗផងដែរ ដោយបច្ចុប្បន្ន ក្រុមហ៊ុន Telcotech គឺជាក្រុមហ៊ុនទី ៣ ហើយ សម្រាប់ឆ្នាំ ២០២១នេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ pnn ចេញផ្សាយថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២១។*

## រយៈពេល៨ខែឆ្នាំនេះ កម្ពុជាទទួលបានផលវារីវប្បកម្មជាង១៥១តោន



*ប្រភព ៖ cnc*

ភ្នំពេញ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី២៣ ខែសីហា បានបង្ហាញថា ចាប់ពីថ្ងៃទី១ ខែមករា រហូតដល់បច្ចុប្បន្ន ផលសរុបវារីវប្បកម្មទទួលបានមានចំនួន ១៥១ ៤៥៧,២៨តោន និងកូនពូជវារីសត្វគ្រប់ប្រភេទមានចំនួន ២៣៨ ៧៥៩ ៩៥២កូន។

ក្នុងនោះផលសរុបនេះបានមកពីវារីវប្បកម្មទឹកសាប រួមមាន ត្រីប្រា ពោ ឆ្តោ រ៉ស់ ឆ្ពិន ព្រលូង ក្រាញ់ អណ្តែង ទីឡាព្យា ត្រីចម្រុះ កង្កែប កន្ធាយ បង្កងទឹកសាប បង្កងអូស្ត្រាលី អន្ទង់ទឹកសាបជាដើម និងវារីវប្បកម្មសមុទ្រ រួមមាន ត្រីឆ្លង់ ត្រីតុកកែ បង្គា ក្តាមថ្ម គ្រែងឈាម សារាយសមុទ្រ គ្រុំចំពុះទា ត្រីផ្ទក់សមុទ្រ និងគ្រែងឈាម។

ការងារស្រាវជ្រាវវារីវប្បកម្ម បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍវារីវប្បកម្មនៅប្រទេសកម្ពុជា ដោយមានក្រុមការងាររដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូរអភិវឌ្ឍន៍នានា បានជំរុញផលិតពូជវារីសត្វឱ្យបានច្រើនប្រភេទ និងមានគុណភាពល្អសម្រាប់ផ្គត់ផ្គង់ការចិញ្ចឹមឱ្យបានតាមតម្រូវការ និងទាន់ពេលវេលា ខណៈដែលពូជមួយចំនួនបាននាំចូលពីប្រទេសវៀតណាមដើម្បីបំពេញតម្រូវការក្នុងស្រុក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cnc ចេញផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១។*

## ស្រូវវស្សាជាច្រើនហិកតា នៅស្រុកក្រឡាញ់ បានក្រៀមស្វិត និងប្រឈមងាប់ដោយសារអត់ទឹក



*ដោយ Sokhom Khon*

ស្រូវវស្សាជាច្រើនហិកតា នៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប បានក្រៀមស្វិត និងប្រឈមងាប់ ខណៈដែលស្រូវនោះ ខ្វះទឹកភ្លៀងស្រោចស្រប់ និងមិនមានប្រភពទឹកបញ្ចូលស្រែ។

កសិករមួយរូបនៅភូមិគោកល្ហុង ឃុំស្រណាល ស្រុកក្រឡាញ់ បានអោយដឹងថា ស្រូវវស្សារបស់លោកមានជាង២ហិកតា បានក្រៀមស្វិតរយៈពេលជាច្រើនថ្ងៃមកហើយ ដោយសារអត់ភ្លៀង ហើយនៅតំបន់គាត់ក៏គ្មានប្រភពទឹកប្រឡាយ ដើម្បីបញ្ចូលស្រែសង្គ្រោះជីវិតស្រូវនោះដែរ។ គ្រោះរាំងស្ងួតនេះ មានរយៈពេល២ខែមកហើយ ស្រូវដែលក្រៀមស្វិតនេះ អាចនឹងងាប់ក្នុងរយៈពេលខ្លីខាងមុខ បើសិនគ្មានភ្លៀងធ្លាក់ទេ។

មេឃុំស្រណាល ស្រុកក្រឡាញ់ បានលើកឡើងថា គ្រោះរាំងស្ងួតខ្លាំង ចាប់ពីចុងខែកក្កដាកន្លងមក ដែលធ្វើឱ្យស្រូវវស្សា នៅឃុំរបស់លោកប្រមាណពី១៥០០ហិកតា ទៅ២ពាន់ហិកតាក្រៀមស្វិត។ ប្រជាកសិករកំពុងបាត់បង់ស្រូវស្រែ ដែលនេះនឹងកាន់តែធ្វើឱ្យប្រជា-

ពលរដ្ឋនៅតំបន់នោះ ធ្វើចំណាកស្រុកបន្ថែមទៀត។ ប្រជាកសិករនៅតំបន់នោះធ្វើស្រែពឹងលើទឹកភ្លៀង បើគ្មានភ្លៀងធ្លាក់ទេគឺស្រូវនោះ មានតែងាប់ប៉ុណ្ណោះ ព្រោះគ្មានប្រភពទឹកដែលអាចនាំបញ្ចូលស្រែកសិករបានឡើយ។
អភិបាលនៃគណៈអភិបាលស្រុកក្រឡាញ់ មានប្រសាសន៍ថា ផលប៉ះពាល់ស្រូវដែលជួបគ្រោះរាំងស្ងួតនោះ មានចំនួន៣ឃុំ ស្មើនឹង១៤ភូមិ ប៉ុន្តែ ស្រូវនោះនៅមិនទាន់ខូចធ្ងន់ធ្ងរនោះទេ ដោយបណ្តូលកណ្តាលរបស់វានៅពណ៌ខៀវនៅឡើយទេ ជារួម ស្រូវនេះវាកំពុងលូតលាស់។ តែស្រូវស្រពោននេះ បើក្នុងរយៈពេល១៥ថ្ងៃមិនមានភ្លៀងធ្លាក់ទេ វាអាចខូចខាតទាំងស្រុង ប្រមាណជិត ១៣ពាន់ហិកតា៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ កម្ពុជាថ្មី ចេញផ្សាយថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិកលើមុខទំនិញនៅក្នុងខែមិថុនាឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា៖ នៅក្នុងខែមិថុនា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់សរុបចំនួន ៦៣៤,៩លានដុល្លារ ដែលមានការធ្លាក់ចុះប្រមាណជា ១៧,៨% បើធៀបនឹងខែឧសភា ឆ្នាំ២០២១។

ជាក់ស្តែង ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់២៨,៨លានដុល្លារ នៅក្នុងខែមិថុនា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ២៤,៤% បើធៀបនឹងខែឧសភា។ ការនាំចូលទំនិញសំខាន់ៗទាំងនេះរួមមាន៖ រថយន្តធ្វើដំណើរ ប្រេងសណ្តែក(soybean oilcake) ផលិតផលស្បែកសត្វ (raw furskin) និងផលិតផលផ្សេងៗទៀត។

ស្របពេលនោះដែរ ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់ប្រមាណជា ៦១២,២ លានដុល្លារ នៅក្នុងខែមិថុនា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រហែល ១៧,៣% បើធៀបនឹងខែឧសភា។ ការនាំចេញនេះ ភាគច្រើនជាប្រភេទទំនិញ រួមមាន៖ កាបូបយួរ កាបូបដាក់លុយ សំលៀកបំពាក់ និងផលិតផលផ្សេងៗទៀត៕ *ដោយ មិត្ត ចន្នី*

| **បរិយាយ** | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **614.5** | **572.7** | **782.1** | **685.7** | **650.3** | **534.9** |
| កំណើន % | | -6.8% | 36.6% | -12.3% | -5.2% | -17.8% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 | 38.1 | 28.8 |
| កំណើន % | | -1.8% | 17.4% | -24.8% | 29.6% | -24.4% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 | 612.2 | 506.1 |
| កំណើន % | | -7.1% | 37.7% | -11.7% | -6.7% | -17.3% |

ប្រភព៖ការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យពាណិជ្ជកម្មសហរដ្ឋអាមេរិក (**គិតជាលានដុល្លារ**)

## តារាងទី២ ៖ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ប្រចាំខែមិថុនា នៅឆ្នាំ២០២១

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ នៅក្នុងខែមិថុនា ឆ្នាំ២០២១នេះ រដ្ឋបាលថ្នាក់ជាតិ បានប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសបានចំនួនសរុប ១៨៨,៣២ប៊ីលានរៀល ដែលមានកំណើនបន្តិចបន្តួចប្រមាណជា០,៩%បើធៀបនឹងខែឧសភា នៃឆ្នាំដដែល។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូលបានប្រមាណជា ១៨៥,៣៧ប៊ីលានរៀល នៅក្នុងខែមិថុនាឆ្នាំ២០២១នេះ ដែលមានកំណើនប្រមាណជា ១,៤% បើធៀបនឹងខែឧសភា។

ក៏ប៉ុន្តែ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញមានចំនួន ២,៩៥ប៊ីលានរៀល នៅក្នុងខែមិថុនា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ២១,៣% បើធៀបនឹងខែឧសភា៕*ដោយ៖ មិត្ត ចន្ទី*

| បរិយាយ(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 159.5 | 153.1 | 238.5 | 106.6 | 186.59 | 188.32 |
| កំណើន(%) | | -4.0% | 55.8% | -55.3% | 75.1% | 0.9% |
| ពន្ធ និងអាករលើការនាំចូល | 156.89 | 150.79 | 233.60 | 103.46 | 182.84 | 185.37 |
| កំណើន(%) | | -3.9% | 54.9% | -55.7% | 76.7% | 1.4% |
| ពន្ធ និងអាករលើការនាំចេញ | 2.64 | 2.35 | 4.92 | 3.12 | 3.75 | 2.95 |
| កំណើន(%) | | -11.0% | 109.4% | -36.6% | 20.2% | -21.3% |

*ប្រភព៖តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែមិថុនាឆ្នាំ២០២១នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ប្រទេសកម្ពុជាបានស្នើឱ្យប្រទេសថៃជួយជំរុញទេសចរណ៍ បន្ទាប់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ មានសភាពធូរស្រាល




*ប្រភព៖postkhmer ២០២១, រូបភាព៖ ហ៊ីន ពិស*

នៅក្នុងជំនួបប្រជុំនៅទីក្រុងបាងកកប្រទេសថៃ រវាងឯកឧត្តម សុខ សុក្រឹត្យា រដ្ឋលេខាធិការក្រសួងទេសចរណ៍កម្ពុជាជាមួយឯកឧត្តម Phiphat Ratchakitprakarn រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងកីឡាប្រទេសថៃ ដើម្បីពិភាក្សា និងពង្រឹងទំនាក់ទំនង វិស័យទេសចរណ៍កម្ពុជា-ថៃ ទាំងក្នុង និងក្រោយដំណាក់កាលនៃជំងឺកូវីដ-១៩។

តាមរយៈជំនួបប្រជុំនេះ ប្រទេសកម្ពុជាបានស្នើឱ្យភាគីខាងប្រទេសថៃដែលមានព្រំដែនជាប់គ្នាជួយសហការ និងចូលរួមលើកកម្ពស់វិស័យទេសចរណ៍អន្តរជាតិឡើងវិញ ខណៈប្រទេសកម្ពុជាមានផែនការបើកទ្វារទទួលភ្ញៀវទេសចរបរទេសចាក់វ៉ាក់សាំងរួចរាល់ ចាប់ពីត្រីមាសទី ៤ ខាងមុខតទៅ ដែលសំណើជាក់លាក់ទាំងនោះ រួម

មាន៖១-ការបង្កើនការផ្តល់អាហារូបករណ៍ទេសចរណ៍ដល់មន្ត្រីទេសចរណ៍កម្ពុជា ២-ការជំរុញផ្នែកឯកជនថៃចូលរួមក្នុងវេទិកាទេសចរណ៍អាស៊ាន ATF2022 នៅខេត្តព្រះសីហនុ ៣-ការបង្កើនកិច្ចសហការក្នុងការរៀបចំកញ្ចប់ទស្សនកិច្ចរួមគ្នាសម្រាប់ទេសចរបរទេស ៤-ការជំរុញចលនាទេសចរណ៍បើកបរឆ្លងដែន ៥-ការជំរុញការអនុវត្តក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ACMEC លើការប្រើប្រាស់ទិដ្ឋាការទោលសម្រាប់ទេសចរបរទេសនៃប្រទេសទី ៣ មកទស្សនាកម្ពុជា-ថៃ និង ៦- ការបង្កើនការផ្សព្វផ្សាយគោលដៅទេសចរណ៍ព្រះរាជាណាចក្រពីរគោលដៅតែមួយ។

ជាការឆ្លើយតប ភាគីប្រទេសថៃបានសន្យានឹងខិតខំបង្កើនការផ្តល់អាហារូបករណ៍ដល់មន្ត្រីទេសចរណ៍កម្ពុជា ចំណែកសំណើផ្សេងៗទៀត អាចនឹងយកទៅពិនិត្យ ព្រមទាំងបានសន្យាបន្តផ្តល់កិច្ចសហការឱ្យកាន់តែជិតស្និទ្ធ និងទូលំទូលាយជាមួយភាគីកម្ពុជា។

បច្ចុប្បន្នរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងទេសចរណ៍ កំពុងរៀបចំផែនការយុទ្ធសាស្ត្រក្នុងការត្រៀមបើកដំណើរការវិស័យទេសសចរណ៍ឡើងវិញ តាមរយៈការស្តារហេដ្ឋារចនាសម្ព័ន្ធនានា ដើម្បីធ្វើយ៉ាងណាជំរុញវិស័យទេសចរណ៍នៅកម្ពុជាឱ្យមានដំណើរការល្អឡើងវិញ។ បន្ថែមពីនេះ ក្រសួងទេសចរណ៍កំពុងសិក្សា និងរៀបចំឯកសារទស្សនទានស្តីពីកញ្ចប់ទេសចរណ៍ចាក់វ៉ាក់សាំងនៅក្នុងគោលដៅពិនិត្យលទ្ធភាពសម្រាប់ប្រទេសដែលមានហានិភ័យទាបបានមកទស្សនានៅកម្ពុជា ក្នុងតំបន់ដែលមានសុវត្ថិភាព ដោយគោរពតាមវិធានសុវត្ថិភាពរបស់ប្រទេសកម្ពុជា គឺធ្វើយ៉ាងណាចូលរួមទប់ស្កាត់ជំងឺកូវីដ ១៩។

របាយការណ៍ក្រសួងទេសចរណ៍បង្ហាញថា ក្នុងឆមាសទី ១ ឆ្នាំ២០២១ កម្ពុជាទទួលបានភ្ញៀវបរទេស ១០២ ៥៦០ នាក់ ធ្លាក់ចុះ ៩១,៣%បើធៀបនឹងឆមាសទី ១ ឆ្នាំ២០២០។ ដោយឡែកសម្រាប់ភ្ញៀវទេសចរជនជាតិថៃ នៅក្នុងអំឡុងពេលនេះមាន ចំនួន ៥១ ២៩០ នាក់ ធ្លាក់ចុះ ៦៧,៥%។ *ដោយ សេន ចន្ទ*

*ប្រភព៖ [postkhmer](), ចេញផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១*

## ប្រទេសវៀតណាមគឺជាទីផ្សារធំសម្រាប់ស្វាយកម្ពុជា



*ប្រភព៖ [ខ្មែរថាមស២០២១, រូបភាព៖ Shutterstock]()*

នៅក្នុងរយៈពេល៧ខែដំបូងឆ្នាំ២០២១ កម្ពុជាបាននាំចេញផ្លែស្វាយស្រស់ចំនួន ១៤០,០០០តោន ឬស្មើនឹង ៨៦,៨% នៃការនាំចេញផ្លែឈើសរុប។

តាមទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកម្ពុជា ការិយាល័យពាណិជ្ជកម្មវៀតណាមបានបង្ហាញថា៖ កម្ពុជាបាននាំចេញផ្លែស្វាយចំនួន១៦១,២២៨ តោន ក្នុងរយៈពេល៧ខែ(មករា-កក្កដា)ឆ្នាំនេះ មានការកើនឡើងដល់២៤៨%ធៀបនឹងឆ្នាំកន្លងទៅ។

ទន្ទឹមនឹងនេះ ក្រៅពីផ្លែស្វាយស្រស់ កម្ពុជាបាននាំចេញដំណាប់ស្វាយប្រមាណជិត១៣,៥២៥តោន ក្នុងនោះ

៧៧ តោននាំចេញទៅប្រទេសវៀតណាម ១ ០០០ តោនទៅប្រទេសថៃ និង១១ ០០០តោនទៅប្រទេសចិន។

បច្ចុប្បន្ន កម្ពុជាបានប្រមូលផលផ្លែស្វាយលើផ្ទៃដីទំហំប្រមាណជា១២៦,៦៦៨ហិចតា ហើយកាលពីឆ្នាំមុន កម្ពុជាបាននាំចេញ ចំនួន៨៤៥,២៧៤តោន ដែលមានទំហំទឹកប្រាក់ចំនួន៤៧៣,២លានដុល្លារអាមេរិក ដែលភាគច្រើននាំចេញទៅប្រទេសវៀតណាម, ថៃ, ចិន, កូរ៉េខាងត្បូង, សិង្ហបុរី, រុស្ស៊ី និងបារាំង។*ដោយ មុំ ចិន្តា*

*ប្រភព៖ ខ្មែរថាម ចេញផ្សាយថ្ងៃទី២៤ ខែសីហាឆ្នាំ២០២១*

## គណនីចរន្តរបស់ប្រទេសម៉ាឡេស៊ីអតិរេក RM ១៤,៤ ប៊ីលានក្នុងត្រីមាសទី២ ឆ្នាំ២០២១




តុល្យភាពគណនីចរន្តរបស់ប្រទេសម៉ាឡេស៊ី មានអតិរេកចំនួន RM១៤,៤ប៊ីលាននៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ កើនឡើង ១៧,២% ធៀបនឹងត្រីមាសមុនដែលមានត្រឹម RM១២,៣ ប៊ីលាន។ អតិរេកគណនីចរន្ត ត្រូវបានរុញច្រានដោយគណនីទំនិញដែលមានអតិរេកចំនួន RM៤០,៧ប៊ីលាន ស្មើនឹង១១,១%ប្រៀបធៀបនឹងត្រីមាសទី១ មានចំនួនRM៣៦,៦ប៊ីលាន ទោះបីជាគណនីសេវាកម្មបានបន្តថយចុះតាំងពីត្រីមាសទី២ក្នុងឆ្នាំ២០២០មកដោយសារតែកាផ្ទុះឡើង នៃជំងឺឆ្លងកូវីដ-១៩។

ការនាំចេញទំនិញនៅក្នុងត្រីមាសទី២ឆ្នាំ២០២១ មានចំនួន RM ២៤៤ ប៊ីលាន កើនឡើង RM១៨,៥ ប៊ីលាន ធៀបនឹងត្រីមាសទី១ ក្នុងនោះការនាំចេញទំនិញភាគច្រើនជាផលិតផល អេឡិចត្រូនិច ប្រេង និងកៅស៊ូដែលបាននាំចេញទៅកាន់ប្រទេស ចិន សង្ហបុរី និងសហរដ្ឋអាមេរិក ។ ចំណែកឯ ការនាំចូលវិញកើនឡើងចំនួន RM១៤,៥ប៊ីលាន ធៀបនឹងរយៈពេលដូចគ្នាក្នុងត្រីមាសកន្លងទៅ។

ការថយចុះនៃឱនភាពគណនីចំណូលបន្ទាប់បន្សំ (Secondary income)ពី RM៣,៦ប៊ីលានក្នុងត្រីមាសទី១ មកត្រឹម RM១,៤ប៊ីលាននៅក្នុងត្រីមាសទី២ ក៏បានចូលរួមចំណែកក្នុងការធ្វើឱ្យមានអតិរេកគណនីចរន្តនៅក្នុងត្រីមាសទី២ផងដែរ។

ទន្ទឹមនេះ គណនីចំណូលបឋម (Primary Income) មានឱនភាព RM៩,៥ប៊ីលាន ធៀបនឹងត្រីមាសទី១ មាន RM៥,៧ប៊ីលាន នេះបង្ហាញឱ្យដឹងថាក្រុមហ៊ុនបរទេសដែលវិនិយោគនៅក្នុងប្រទេសម៉ាឡេស៊ី អាចរកបានប្រាក់ចំណូលខ្ពស់នៅក្នុងត្រីមាសទី២។ ចំណែកឯក្រុមហ៊ុនរបស់ម៉ាឡេស៊ីដែលវិនិយោគនៅក្រៅប្រទេសក៏រកប្រាក់ចំណូលបានខ្ពស់ផងដែរ។*ដោយមុំ ចិន្តា*

## តារាងសមាសធាតុរបស់គណនីចរន្តតាមត្រីមាសគិតជាប៊ីលានរីងហ្គីត(RM)

| គិតជាត្រីមាស | គណនីចរន្ត | ទំនិញ | សេវាកម្ម | ចំណូលបឋម | ចំណូលបន្ទាប់បន្សំ |
|---|---|---|---|---|---|
| Q4-2019 | **7,404** | 32,653 | (4,013) | (15,685) | (5,551) |
| Q1-2020 | **8,840** | 28,851 | (7,643) | (7,187) | (5,181) |
| Q2-2020 | **7,695** | 25,833 | (12,370) | (3,827) | (1,941) |
| Q3-2020 | **24,374** | 41,468 | (13,855) | (10,397) | 7,158 |
| Q4-2020 | **18,629** | 42,557 | (14,049) | (7,173) | (2,706) |
| Q1-2021 | **12,293** | 36,611 | (14,950) | (5,732) | (3,636) |
| Q2-2021 | **14,411** | 40,665 | (15,420) | (9,458) | (1,376) |

*ប្រភព៖ Department of statistics Malaysia official portal*

## វិស័យនាំចេញថៃ បន្តកើនឡើងនៅខែកក្កដា ថ្វីបើមានការបន្តផ្ទុះឡើងនៃវិបត្តិជំងឺកូវីដ-១៩


STILL GROWING

Exports, a key driver of Thailand's growth, increased 20.2% year-on-year in July after a robust rise of 43.8% in June on growing global demand.

| Unit: US$ million | July 2021 | Jan-July, 2021 |
|---|---|---|
| Export value | 22,650.83 | 154,985.48 |
| | +20.2% | +16.2% |
| Import value | 22,467.37 | 152,362.86 |
| | +45.9% | +28.7% |
| Trade balance | +183.46 | +2,622.62 |

Top 10 Thai Export Products - July 2021

| Year-on-year % change | July 2021 | Jan-July, 2021 |
|---|---|---|
| Automobiles and parts | 39.2 | 53.1 |
| Computers and parts | 19.3 | 19.1 |
| Rubber products | 15.9 | 36 |
| Gems and jewellery | -47.2 | -54.1 |
| Plastic pellets | 57.8 | 43.1 |
| Chemicals | 54 | 41.7 |
| Fresh, chilled, frozen, and dried fruits | 122.8 | 53.6 |
| Oil | 70.8 | 37.5 |
| Electrical integrated circuits | 25.9 | 19.4 |
| Machinery and parts | 26 | 26 |

Source: Trade Policy and Strategy Office    BANGKOK POST GRAPHICS

*ប្រភព៖ Bangkok Post ២០២១*

ថ្វីបើជំងឺកូវីដ-១៩នៅតែបន្តផ្ទុះឡើង នៅក្នុងប្រទេសថៃ វិស័យនាំចេញ បានបន្តនូវសន្ទុះកំណើន ក្នុងរយៈពេល ៥ខែជាប់គ្នា ដោយនៅក្នុងខែកក្កដា ឆ្នាំ២០២១នេះ ការនាំចេញបានកើនឡើង ២០,២% បើធៀបនឹងខែកក្កដា ឆ្នាំមុន។ គួរបញ្ជាក់ថា កំណើននៃការនាំចេញនេះ បណ្តាលមកពី ការងើបឡើងវិញដ៏ខ្លាំងនៃសេដ្ឋកិច្ចពិភពលោក ការធ្លាក់ចុះនៃតម្លៃលុយបាត ការកើនឡើងនៃតម្លៃប្រេង និងការជំរុញការនាំចេញដោយក្រសួងពាណិជ្ជកម្ម និងវិស័យឯកជន។

យោងតាមក្រសួងពាណិជ្ជកម្ម តម្លៃនៃការនាំចេញសរុប (ឆ្លងកាត់គយ, Custom-cleared exports)បានកើនដល់ ២២,៦៥ប៊ីលានដុល្លារ ខណៈការនាំចូល កើនដល់ ២២,៤៧ប៊ីលាន(កំណើន ៤៥,៩%) នាំឱ្យតុល្យភាពពាណិជ្ជកម្ម មានអតិរេកសរុប ១៨៣,៤៦លានដុល្លារ។ បើគិតសម្រាប់រយៈពេល ៧ខែដំបូង ក្នុងឆ្នាំ២០២១វិញ វិស័យនាំចេញ មានកំណើនប្រមាណជា ១៦,២% នាំឱ្យតម្លៃសរុបនៃការនាំចេញ កើនដល់ ១៥៤,៩៩ប៊ីលានដុល្លារ ស្របពេលដែរ វិស័យនាំចូលសរុប មានកំណើន ២៨,៧% ពោលគឺ តម្លៃសរុបនៃការនាំចូល កើនដល់ ១៥២,៣៦ប៊ីលានដុល្លារ និងជាលទ្ធផល មានអតិរេកពាណិជ្ជកម្មសរុប ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២១ មានចំនួន ២,៦២ប៊ីលានដុល្លារ។ ***ដោយ ជា សិរីរតន៍***

*ប្រភព៖ Bangkok Post ចេញផ្សាយ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១*

## ក្រសួងពាណិជ្ជកម្មស្នើ អ្នកនាំទំនិញទៅអង់គ្លេស ផ្តល់យោបល់លើ សេចក្តីព្រាងយន្តការអនុគ្រោះពន្ធ



*រូបថត ៖ ហេង ជីវ៉ន*

ក្រសួងពាណិជ្ជកម្មបានអំពាវនាវដល់អ្នកនាំចេញទាំងអស់នៅកម្ពុជា ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងយន្តការអនុគ្រោះពន្ធទូទៅថ្មីសម្រាប់នាំចេញទំនិញទៅកាន់ចក្រភពអង់គ្លេស។

ចក្រភពអង់គ្លេសផ្តល់ឱកាសឱ្យភាគីពាក់ព័ន្ធចូលរួមប្រឹក្សាយោបល់សាធារណៈ លើសេចក្តីព្រាងយន្តការអនុគ្រោះពន្ធទូទៅថ្មីនេះ ដើម្បីប្រមូលធាតុចូល និងសំណូមពរតាមរយៈការបំពេញកម្រងសំណួរ ដើម្បីចូលរួមកែសម្រួលលក្ខខណ្ឌតម្រូវ និងនីតិវិធីឱ្យមានលក្ខណៈងាយស្រួល និងសាមញ្ញ ប្រកបដោយ តម្លាភាព និងបរិយាប័ន្ន។ បន្ទាប់ពីទទួលបានធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធ ចក្រភពអង់គ្លេសនឹងពិនិត្យសម្រេចដាក់ចេញនូវប្រព័ន្ធអនុគ្រោះពន្ធទូទៅថ្មីមួយសម្រាប់អនុវត្តនៅឆ្នាំ២០២២ ខាងមុខ។ រដ្ឋាភិបាលអង់គ្លេសបានចាប់ផ្តើមធ្វើការពិគ្រោះយោបល់លើច្បាប់ពាណិជ្ជកម្មថ្មី ដើម្បីបង្កើនពាណិជ្ជកម្មជាមួយបណ្តាប្រទេសមានប្រាក់ចំណូលទាប រួមទាំងកម្ពុជា។

សេចក្តីព្រាងយន្តការអនុគ្រោះពន្ធទូទៅថ្មីនេះ នឹងអនុវត្តចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៧០ នៅពេលបច្ចុប្បន្ន និងរួមទាំងការកែលម្អ លក្ខខណ្ឌមួយចំនួន ដូចជា ពន្ធនាំចូលកាន់តែទាប និងច្បាប់នៃលក្ខខណ្ឌតម្រូវប្រភពដើមកាន់តែងាយស្រួលសម្រាប់ប្រទេសជាច្រើន ដែលនាំចេញទំនិញទៅចក្រភពអង់គ្លេស ហើយអាចឱ្យប្រទេសទាំងនោះធ្វើពិពិធកម្មការនាំចេញ និងធ្វើឱ្យសេដ្ឋកិច្ចពួកគេរីកចម្រើន។

ក្រសួងពាណិជ្ជកម្ម បានអំពាវនាវដល់ផលិតករ ឬអ្នកនាំចេញទាំងអស់ ចូលរួមបំពេញកម្រងសំណួរ ឱ្យបានត្រឹមថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១។

ផែនការពាណិជ្ជកម្មបណ្តាប្រទេសកំពុងអភិវឌ្ឍន៍របស់ចក្រភពអង់គ្លេសនឹងអនុវត្តចំពោះប្រទេសចំនួន ៤៧ ក្នុងក្របខ័ណ្ឌប្រទេសអភិវឌ្ឍន៍តិចតួចបំផុត (LDCF) និងបណ្តាប្រទេស ២៣ បន្ថែមទៀតដែលត្រូវចាត់ថ្នាក់ដោយធនាគារពិភពលោក ជាប្រទេសមានប្រាក់ចំណូលទាប និងប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប។ កម្ពុជាទទួលស្វាគមន៍រាល់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទាំងឡាយណាដែលផ្តល់ប្រយោជន៍នៅក្នុងការពង្រីកទីផ្សារ និងការនាំចេញទំនិញ។ សព្វថ្ងៃកម្ពុជាទទួលបាននូវភាពអនុគ្រោះពាណិជ្ជកម្មរួចហើយ គឺប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម GSP ពីចក្រភពអង់គ្លេសដែលផ្តល់ ឱ្យប្រទេសកំពុងអភិវឌ្ឍន៍តិចតួច។ បើប្រព័ន្ធអនុគ្រោះថ្មីនេះមានលក្ខណៈងាយស្រួលជាងប្រព័ន្ធអនុគ្រោះចាស់ GSP នោះកម្ពុជា នឹងមានឱកាសច្រើនក្នុងការពង្រីកទីផ្សាររបស់យើងទៅកាន់ចក្រភពអង់គ្លេស។

អគ្គលេខាធិការរងសមាគមរោងចក្រកាត់ដេរនៅកម្ពុជាបានប្រាប់ថា លោកបានជូនព័ត៌មាននេះដល់សមាជិករបស់សមាគមរួចរាល់ហើយដើម្បីឱ្យពួកគេចូលរួមក្នុងការឆ្លើយតបទៅតាមតម្រូវការរបស់ចក្រភពអង់គ្លេស។ ការចូលរួមផ្តល់យោបល់គឺមានភាពចាំបាច់ណាស់នៅក្នុងអភិបាលកិច្ចប្រជាធិបតេយ្យ។

ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងចក្រភពអង់គ្លេសបានបន្តកើនឡើងជាលំដាប់ ជាក់ស្តែងក្នុងរយៈពេល ៥ ខែដើមឆ្នាំនេះពាណិជ្ជកម្មរវាងប្រទេសទាំង ២ មានតម្លៃ ២៥៨,៤៥ លានដុល្លារក្នុងនោះ កម្ពុជានាំទៅចក្រភពអង់គ្លេស ២៣៩,៧៣ លានដុល្លារ ខណៈកម្ពុជានាំចូល ១៨,១៧ លានដុល្លារ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២១។*

## សេដ្ឋកិច្ចសកល

### វិបត្តិជំងឺរាតត្បាត បានគម្រាមកំហែងដល់វឌ្ឍនភាពនៃគោលដៅអភិវឌ្ឍពិភពលោករបស់អាស៊ី-ប៉ាស៊ីហ្វិក



*ប្រភព៖ Reuters ២០២១, រូបភាព៖ Adnan Abidi*

ធនាគារអភិវឌ្ឍន៍អាស៊ី ឬហៅកាត់ថា ADB បានលើកឡើងកាលពីថ្មីៗនេះថា(ថ្ងៃទី២៤ ខែកក្កដា) វិបត្តិជំងឺរាតត្បាតកូវីដ-១៩ បានរុញច្រានប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី ប្រមាណជា ៨០លាននាក់ ឱ្យធ្លាក់ចូលទៅក្នុងភាពក្រីក្រខ្លាំង(ឆ្នាំ២០២០) និងបានគម្រាមកំហែងលើវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍពិភពលោក ក្នុងការដោះស្រាយភាពក្រីក្រ និងភាពអត់ឃ្លាននៅត្រឹមឆ្នាំ២០៣០។

យោងតាមការធ្វើ Simulation ដោយធនាគារ ADB អត្រាភាពក្រីក្រខ្លាំងក្នុងប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីត្រូវបានព្យាករថា មានអត្រាខ្ពស់ជាងការរំពឹងទុកចំនួន ២ពិន្ទុភាគរយ សម្រាប់ឆ្នាំ២០២០។ ជាក់ស្តែង ប្រសិនបើគ្មានវិបត្តិជំងឺកូវីដ-១៩ទេ អត្រានេះ អាចនឹងធ្លាក់ចុះពី ៥,២% ក្នុងឆ្នាំ២០១៧ ទៅ ២,៦% ក្នុងឆ្នាំ២០២០។ ម៉្យាង គួរឱ្យកត់សម្គាល់ផងដែរថា អត្រានេះ អាចនឹងខ្ពស់ជាងនេះទៀត បើគិតបញ្ចូលបញ្ហាវិសមភាព ក្នុងវិស័យសុខាភិបាល វិស័យអប់រំ និងការបង្អាក់រំខានក្នុងការងារ។

បន្ថែមពីនេះទៀត គួរបញ្ជាក់ថា ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍចំនួន ៤៦ និងប្រទេសអភិវឌ្ឍចំនួន ០៣ នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៅឆ្នាំ២០២០ ក្នុងនោះមានតែប្រទេសចំនួន ០១ ក្នុងចំណោមប្រទេសសរុបចំនួន ០៤ ដែលមានកំណើនសេដ្ឋកិច្ច។ ទន្ទឹមនេះដែរ តំបន់នេះ បានបាត់បង់ម៉ោងធ្វើការ ប្រមាណជា ៨%នៃម៉ោងធ្វើការសរុប ស្របពេលមានកំណើននៃអត្រាគ្មានការងារ ដែលការណ៍នេះ បានប៉ះពាល់ដល់គ្រួសារក្រីក្រ និងកម្មករក្រៅប្រព័ន្ធ។

ជាក់ស្តែង ការខូចខាតសេដ្ឋកិច្ចដែលបង្កឡើងដោយវិបត្តិជំងឺរាតត្បាត បានដាក់សម្ពាធបន្ថែមទៅលើបញ្ហាប្រឈម ក្នុងការសម្រេចនូវគោលដៅអភិវឌ្ឍពិភពលោកដែលមានកាលកំណត់ត្រឹមឆ្នាំ២០៣០។

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១*

### កូវីដ Delta ធ្វើឱ្យក្តីសង្ឃឹមនៃការងើបឡើងវិញសេដ្ឋកិច្ចនៅអាស៊ីធ្លាក់ចុះ



*អ្នកជំងឺកូវីដនៅទីក្រុង Quezon ប្រទេសហ្វីលីពីន ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១។ រូបថតដោយ៖ Reuters*

កំណើននៃការរីករាលដាលកូវី១៩ Delta មានការកើនឡើងយ៉ាងគំហុក ខណៈដែលចំនួនអ្នកចាក់វ៉ាក់សាំង

មានអត្រាទាប ដែលជាហេតុធ្វើឱ្យសេដ្ឋកិច្ចនៅអាស៊ីរងគ្រោះកាន់តែខ្លាំងជាងឆ្នាំមុន។ ខណៈដែលសូចនាករសេដ្ឋកិច្ច និងអាជីវកម្មបន្តបង្ហាញពីការស្ទុះងើបឡើងវិញយ៉ាងខ្លាំង បើធៀបទៅនឹងឆ្នាំ២០២០ ស្រាប់តែក្តីសង្ឃឹមបានធ្លាក់ចុះ។ ជាក់ស្តែងប្រាក់ចំណេញប្រចាំត្រីមាសរបស់ក្រុមហ៊ុនធំៗនៅអាស៊ីបានធ្លាក់ចុះចាប់ពីខែកក្កដា ដល់ខែកញ្ញា ចំនួន ៦,១៩% នេះបើយោងតាមការវិភាគទិន្នន័យរបស់ Reuters ទៅលើក្រុមហ៊ុនចំនួន ១ ០៦៩ ដែលមានដើមទុនតិចបំផុត ១ប៊ីលានដុល្លារ។

នៅក្នុងអំលុងពេលដ៏ខ្លីខាងមុខ សេដ្ឋកិច្ចអាស៊ីត្រូវពឹងផ្អែកលើកំណើននៃការចាក់វ៉ាក់សាំងនៅអាស៊ីអាគ្នេយ៍ និងស្ថិតនៅលើការវិវឌ្ឍសេដ្ឋកិច្ចរបស់ចិន ព្រោះអាស៊ីអាគ្នេយ៍គឺជាមូលដ្ឋានគ្រឹះផលិតកម្ម។ ក្រុមហ៊ុន Toyota ដែលជាក្រុមហ៊ុនផលិតរថយន្តធំជាងគេទី២ នៅក្នុងពិភពលោក បានកាត់បន្ថយការផលិតដល់ទៅ ៤០% នៅក្នុងខែកញ្ញាខាងមុខ ដោយសារតែការបិតខ្ទប់ និងការរីករាលដាលកូវីដ១៩ នៅអាស៊ីអាគ្នេយ៍។ ដោយសារផលប៉ះពាល់នៃការបិតខ្ទប់នៅអាស៊ីអាគ្នេយ៍ វាបានផ្តល់ផលប៉ះពាល់អវិជ្ជមាននៅក្នុងវិស័យសេវាកម្ម និងកម្មន្តសាល ហើយភាគច្រើននៃសង្វាក់ផលិតកម្មទាំងនោះផលិតគ្រឿងបន្លាស់ និងផលិតផលពាក់កណ្តាលសម្រេច ជាពិសេសនៅប្រទេសថៃ វៀតណាម និងម៉ាឡេស៊ី។ រីឯការលក់រថយន្តរបស់ចិនក្នុងខែកក្កដាធ្លាក់ចុះ ១១,៩% បើធៀបទៅនឹងខែកក្កដាឆ្នាំទៅ៕ *ដោយ វង្ស ច័ន្ទស្មើដារា ប្រភព៖ គេហទំព័រ Bangkok Post ចេញផ្សាយថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១*

## IMFបែងចែកទុនបម្រុង៦៥០ប៊ីលានដុល្លារជួយទ្រទ្រង់សេដ្ឋកិច្ចពិភពលោក




*រូបថតដោយ៖ Ludovic Marin/Pool via REUTERS/Files*

អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) បានធ្វើការបែងចែកទុនបម្រុងរូបិយវត្ថុអន្តរជាតិដើម្បីជួយទ្រទ្រង់ដល់សេដ្ឋកិច្ចពិភពលោក និងប្រទេសដែលជាសមាជិក IMF។ ទឹកប្រាក់នេះត្រូវបានប្រើប្រាស់ដើម្បីជួយឱ្យប្រទេសសមាជិកទាំងនោះកាត់បន្ថយការពឹងផ្អែកលើបំណុលដែលមានអត្រាការប្រាក់ខ្ពស់នៅក្នុងស្រុក និងបំណុលក្រៅប្រទេស។ ការផ្តល់ជូននូវ SDR ថ្មីនេះនឹងអាចផ្តល់លទ្ធភាពឱ្យប្រទេសអ្នកមានជួយដល់ប្រទេសនានាដែលកំពុងតែរងគ្រោះធ្ងន់ធ្ងរដោយសារតែវិបត្តិកូវីដ១៩។

ទឹកប្រាក់ចំនួន ២៧៥ប៊ីលាននៃមូលនិធិដែលបានផ្តល់ជូននឹងត្រូវប្រគល់ទៅឱ្យប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចកំពុងងើបឡើង។ ចំណែកឯទឹកប្រាក់ចំនួន ២១ប៊ីលានទៀតនឹងត្រូវផ្តល់ជូនដល់ប្រទេសដែលមានចំណូលទាប។ ក្នុងនោះ IMF បានលើកទឹកចិត្តឱ្យប្រទេសអ្នកមានដែលមានសិទ្ធិទទួល

បានជំនួយនេះគួរផ្ទេរសាច់ប្រាក់នោះជួយដល់ប្រទេសក្រីក្រដែលកំពុងតែត្រូវការជំនួយ ដើម្បីជួយកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចនៅប្រទេសដែលមានប្រាក់ចំណូលទាប។ គួររំលឹកផងដែរថា កាលពីឆ្នាំ ២០០៩ ប្រទេសដែលជាសមាជិក IMF បានទទួលទឹកប្រាក់បម្រុងពី IMF ចំនួន ២៥០ប៊ីលាន SDR ដើម្បីដោះស្រាយវិបត្តិហិរញ្ញវត្ថុកាលពីឆ្នាំ២០០៨។

បន្ថែមពីនោះ ទឹកប្រាក់នេះអាចនឹងត្រូវបានប្រើប្រាស់សម្រាប់ប្រទេស ដែលកំពុងតែរងផលប៉ះពាល់ខ្លាំងដោយសារការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងសម្រាប់ដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ។ មួយវិញទៀត សាច់ប្រាក់នោះក៏នឹងត្រូវបានប្រើប្រាស់ដើម្បីទ្រទ្រង់ដល់ការផ្តល់ប្រាក់កម្ចីសម្រាប់ធនាគារអភិវឌ្ឍន៍ពហុភាគីផងដែរ។ ដូចនេះប្រទេសដែលទទួលបានការជួយជ្រោមជ្រែងពី IMF អាចប្រើប្រាស់សាច់ប្រាក់នោះដើម្បីទ្រទ្រង់សេដ្ឋកិច្ចរបស់ខ្លួន និងដើម្បីទប់ស្កាត់វិបត្តិកូវីដ១៩ មួយជំហានទៀត។ ប៉ុន្តែ IMF បានព្រមានថាប្រទេសទាំងនោះមិនត្រូវប្រើអត្ថប្រយោជន៍នៃគោលនយោបាយសារពើពន្ធដែលទទួលបានពី IMF ដើម្បីពន្យារពេលធ្វើកំណែទម្រង់សេដ្ឋកិច្ច ឬពន្យារពេលរៀបចំបំណុលឡើងវិញឡើយ៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ RUETERS ចេញផ្សាយថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី៣០ ខែសីហា ឆ្នាំ២០២១

- កំណើននៃការលក់រាយនៅប្រទេសជប៉ុន បានកើនឡើង ០,១% នៅខែមិថុនាឆ្នាំ ២០២១ ទាបជាងការរំពឹងទុករបស់ទីផ្សារ ០,២%
- កំណើននៃការលក់រាយនៅអេស្ប៉ាញ បានកើនឡើង ០,២០%នៅក្នុងខែមិថុនាឆ្នាំ ២០២១

ថ្ងៃអង្គារ ទី៣១ ខែសីហា ឆ្នាំ២០២១

- អត្រានីកម្មភាព តាមរដូវនៅប្រទេសអាឡឺម៉ង់នៅខែមិថុនាឆ្នាំ ២០២១ មិនផ្លាស់ប្តូរពីខែមុន
- សេដ្ឋកិច្ចបារាំងបានពង្រីក ០,៩%ក្នុងមួយត្រីមាសនៅត្រីមាសទី ២ ឆ្នាំ ២០២១

ថ្ងៃពុធ ទី០១ ខែកញ្ញា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់កូរ៉េខាងត្បូងបានធ្លាក់ចុះមកនៅត្រឹម ១,៧៦ ពាន់លានដុល្លារនៅខែកក្កដាឆ្នាំ ២០២១
- កំណើនផលិតផលក្នុងស្រុកសរុប (GDP) នៅអូស្ត្រាលីបានកើនឡើង ១,១០% នៅត្រីមាសទី ១ ឆ្នាំ ២០២១ ធៀបនឹងត្រីមាសដូចគ្នានៃឆ្នាំមុន

ថ្ងៃព្រហស្បតិ៍ ទី០២ ខែកញ្ញា ឆ្នាំ២០២១

- កំណើន អតិរេកពាណិជ្ជកម្មរបស់ប្រេស៊ីល ដល់ ៧,៤ ពាន់លានដុល្លារនៅខែកក្កដាឆ្នាំ ២០២១
- ការលក់យានយន្តសរុបនៅសហរដ្ឋអាមេរិកបានធ្លាក់ចុះ ក្នុងខែមិថុនាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី០៣ ខែកញ្ញា ឆ្នាំ២០២១

- ឱនភាពថវិការបស់រដ្ឋាភិបាលបារាំង បានកើនឡើងដល់ ១៣១,៣ ពាន់លានអឺរ៉ូនៅខែមករាដល់ខែមិថុនាឆ្នាំ ២០២១៕